ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ០១២/១៨ រ.ប.ក.

# របាយការណ៍បូកសរុបសកម្មភាព
# និងលទ្ធផលការងារបង្ការ-ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស
# និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំខែធ្នូ និងទិសដៅខែមករា ឆ្នាំ២០១៨

## I. ស្ថានភាពទូទៅ

ក្នុងខែធ្នូ ឆ្នាំ២០១៧ ស្ថានភាពបទល្មើសជួញដូរមនុស្ស ត្រូវបានរកឃើញ និងបង្ក្រាបជាបន្តបន្ទាប់ គួរឲ្យកត់សម្គាល់ ។ ដោយឡែកការធ្វើចំណាកស្រុកឆ្លងដែន ឬទេសន្តរប្រវេសន៍ ក៏មានស្ថានភាពមិនប្រក្រតី ដែលមានប្រជាពលរដ្ឋចាកចេញទៅធ្វើការនៅប្រទេសថៃរហូតដល់ជាងមួយលាននាក់ ទាំងស្របច្បាប់ ទាំងមិនមានឯកសារច្បាប់។ ថ្មីៗនេះ រាជរដ្ឋាភិបាលថៃ បានចេញគោលការណ៍រឹតបន្តឹងពលករទេសន្តរប្រវេសន៍ ដែលរស់នៅ និងធ្វើការខុសច្បាប់ក្នុងប្រទេសថៃ។ ដើម្បី ជាដំណោះស្រាយ រដ្ឋាភិបាលថៃបានទុករយៈពេល៦ខែ ពីខែមិថុនា ដល់ចុងខែធ្នូ ឆ្នាំ២០១៧ ដើម្បីឲ្យពលកររៀបចំបំពេញបែបបទឯកសារស្របច្បាប់ ជាពិសេសលិខិតឆ្លងដែន ឲ្យទាន់ពេលវេលា ពុំនោះទេពលករទាំងនោះនឹងត្រូវបញ្ជូនត្រឡប់មកប្រទេសដើមវិញ។ រាជរដ្ឋាភិបាលកម្ពុជា បានបញ្ជូនក្រុមការងារផ្ដល់ភាពស្របច្បាប់ ជូនពលករ ជិតបួនរយនាក់ ដើម្បីផ្ដល់លិខិតឆ្លងដែន និងពន្លឿនការបំពេញបែបបទស្របច្បាប់ នៅទីក្រុងបាងកក ខេត្តរ៉ៃយ៉ង ឆាកធឹងសាវ និងខេត្តប៉ាធុមថានី ។ ទោះបីជាយ៉ាងនេះក្ដី ក៏នៅមានពលករប្រមាណជាជាង៣០ម៉ឺននាក់ទៀត ដែលរាជរដ្ឋាភិបាលកម្ពុជា ត្រូវបានសហការជាមួយរាជរដ្ឋាភិបាលថៃ ដើម្បីផ្ដល់ឯកសារស្របច្បាប់ ជូនប្រជាពលរដ្ឋខ្មែរជាបន្តបន្ទាប់។ ប្រមុខរាជរដ្ឋាភិបាលរបស់យើង បានយកចិត្តទុកដាក់បំផុតចំពោះប្រជាពលរដ្ឋ ធ្វើទេសន្តរប្រវេសយ៍នៅក្រៅប្រទេស។

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន **គ.ជ.ប.ជ** ជាសេនាធិការ បានបន្តសម្របសម្រួល ពង្រឹងកិច្ចសហការជាមួយដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធ ប្រមូលផ្តុំកម្លាំងចូលរួមរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព រាជធានី-ខេត្ត ដើម្បីបង្កើនកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរកដំណោះស្រាយបញ្ហាប្រឈមនានា។ របាយការណ៍ដែលអគ្គលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទទួលបាន ៖

- ពីបណ្ដាក្រសួង ស្ថាប័ន ថ្នាក់ជាតិ មានក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រុមការពារជនរងគ្រោះ) អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) អគ្គនាយកដ្ឋានអន្តោប្រវេសន៍ កងរាជអាវុធហត្ថលើផ្ទៃប្រទេស។
- សម្រាប់បណ្ដាស្ថាប័ន ថ្នាក់ក្រោមជាតិ មានលេខាធិការដ្ឋាន**២០**ខេត្ត បានផ្ដល់របាយការណ៍ និងរាជធានីភ្នំពេញ ,កែប, ពោធិ៍សាត់, ត្បូងឃ្មុំ និងខេត្តកំពង់ស្ពឺ មិនបានផ្ដល់របាយការណ៍។

ជាលទ្ធផល ដែលសម្រេចបានក្នុងខែធ្នូ ឆ្នាំ២០១៧នេះ មានដូចខាងក្រោម៖

## II. ការអនុវត្តតាមផែនការយុទ្ធសាស្ត្រសកម្មភាពជាតិ (២០១៤-២០១៨)

### ក. ពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និងលើកកម្ពស់សហប្រតិបត្តិការ

ក.១ ការងារច្បាប់ និងគោលនយោបាយជាតិ

ក.១.១-កិច្ចការច្បាប់

❖ **លិខិតបទដ្ឋានដែលកំពុងរៀបចំ**

- សេចក្តីព្រាងច្បាប់ ស្តីពី "**ការគ្រប់គ្រងការពពោះជំនួស**" (ក្រសួងកិច្ចការនារី)
- សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិ "**សម្រាប់អនុវត្តល័ក្ខខ័ណ្ឌការងារកម្មករការងារផ្ទះ**" (ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)
- សេចក្តីព្រាងគោលនយោបាយ ស្តីពី "**កិច្ចការការពារកុមារតាមសាលារៀន**" (ក្រសួងអប់រំ យុវជន និងកីឡា)
- **ក្រសួងយុត្តិធម៌** បានរៀបចំសេចក្តីព្រាងសន្ធិសញ្ញា និងកំពុងពិភាក្សារួមមាន៖
  - សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" (**ច្បាប់ជាតិ**)
  - សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ សាធារណរដ្ឋកូរ៉េ រដ្ឋាភិបាលបារាំង និងរដ្ឋាភិបាលរុស្សី។
  - សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី"**បត្យាប័ន**"រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលឥណ្ឌា។
  - សេចក្តីព្រាង កិច្ចព្រមព្រៀង ស្តីពី"**បញ្ជូនទណ្ឌិត**" រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលអង់គ្លេស រដ្ឋាភិបាលប៉េរូ សាធារណរដ្ឋប្រជាមានិតឡាវ និងរដ្ឋាភិបាលរុស្សី និង
  - សេចក្តីព្រាងច្បាប់ ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។

ក.១.២-**លិខិបទដ្ឋានគតិយុត្តិពាក់ព័ន្ធ**

- **ក្រសួងយុត្តិធម៌**បានអនុម័ត បញ្ចូលឯកសារបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់អាស៊ានសម្រាប់ព្រះរាជអាជ្ញា និងតុលាការ ដើម្បីដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់រាជបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ។

ក.១.៣-អនុស្សរណៈ

❖ **អនុស្សរណៈដែលបានចុះហត្ថលេខា**

- **ប្រមុខរដ្ឋាភិបាលអាស៊ាន** បានចុះហត្ថលេខារួមគ្នាលើកិច្ចព្រមព្រៀងការពារពលករចំណាកស្រុកអាស៊ាន ស្តី"**ពីម្ចាស់ប្រទេសបញ្ជូន និងទទួលយកពលករក្នុងតំបន់អាស៊ាន**" នៅប្រទេសហ្វីលីពីន (ថ្ងៃទី១៣-១៤ ខែវិច្ឆិកា ឆ្នាំ២០១៧)។

❖ **អនុស្សរណៈកំពុងរៀបចំ**

- **គណៈកម្មាធិការជាតិ គ.ជ.ប.ជ** ត្រៀមចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយប្រទេសឥណ្ឌា ស្តីពី "**កិច្ចសហប្រតិបត្តិការបង្ការ ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស**"។
- **ក្រសួងទេសចរណ៍** ត្រៀមចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាពជាមួយអង្គការ Friends International។

### ខ.ការបង្ការទប់ស្កាត់

**ខ.១-កាត់បន្ថយភាពរងគ្រោះដល់ជនមុខសញ្ញារងគ្រោះ៖**

ប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ចំនួន០៥ គឺប៉ុស្តិ៍ប៉ោយប៉ែត, អូរស្មាច់, ដូង, ដាំ និងប៉ុស្តិ៍ព្រំ បានជួយសម្រួល និងផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ ចំនួន១៨.៦៤៣ក្បាល ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន (**របាយការណ៍អគ្គនាយកដ្ឋានអន្តោប្រវេសន៍**)។

**ខ.២-ការអប់រំ ផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ**

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)** បានសហការជាមួយអង្គការដៃគូមួយចំនួន (USAID, WINROCK, The Asia Foundation, UN-ACT, Terre des Hommes, IJM IOM, APLE, Cambodia Acts... ) ផលិតសម្ភារៈផ្សព្វផ្សាយអប់រំ ក្នុងកម្មវិធីយុទ្ធនាការ នៃទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ ធ្នូ លើកទី១១ ឆ្នាំ២០១៧ នៅរាជធានីភ្នំពេញ ដែលមានអ្នកចូលរួមប្រមាណ**៣.២៣២**នាក់ ជាថ្នាក់ដឹកនាំកំពូលសំខាន់ៗ ក្នុងស្ថាប័ននីតិបញ្ញត្តិ រាជរដ្ឋាភិបាល និងតុលាការ អង្គទូតនានាដែលមាននិវេសនដ្ឋាននៅកម្ពុជា អាជ្ញាធរ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ តំណាងផ្នែកសាសនា និយោជក កម្មករ និយោជិត សាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ និស្សិត សិស្សានុសិស្ស និងប្រជាពលរដ្ឋ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ និងតំណាងដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។
- **គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) និងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត** ចំនួន**១៧**ខេត្តៈ (ខេត្តបាត់ដំបង, ព្រៃវែង, ព្រះវិហារ, កំពង់ឆ្នាំង, ពោធិ៍សាត់, ព្រះសីហនុ, កណ្តាល បន្ទាយមានជ័យ, មណ្ឌលគិរី, ឧត្តរមានជ័យ, កំពត, កោះកុង, សៀមរាប, កំពង់ចាម, កំពង់ធំ, តាកែវ និងខេត្តស្វាយរៀង) បានសហការជាមួយអង្គការដៃគូ ផលិតសម្ភារៈផ្សព្វផ្សាយអប់រំ ក្នុងកម្មវិធីយុទ្ធនាការ នៃទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១៧ ដែលមានអ្នកចូលរួមចំនួន**៥៣៥.៦០៧**នាក់ (ស្រី**១០២.៩១៤**នាក់) ជាថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក ភូមិ ឃុំ អាជ្ញាធរ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ មន្ទីរពាក់ព័ន្ធនានា សាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ និស្សិត សិស្សានុសិស្ស និងប្រជាពលរដ្ឋ។

ដោយឡែកស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ និងសមត្ថកិច្ចពាក់ព័ន្ធ សហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងវេទិកាសាធារណៈនៃការអនុវត្តគោលនយោបាយ **"ភូមិ-ឃុំមានសុវត្ថិភាព"** ដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋ បានចំនួន**២.២៨៥**លើក ដែលមានអ្នកចូលរួមសរុបចំនួន**១២៦.៥៨៧**នាក់ (បើប្រៀបធៀបនឹងខែមុន មានចំនួនត្រឹមតែ**៥៣៣.៥៥០**នាក់) ថយចុះ**៤០៦.៩៦៣**នាក់ ស្មើនឹង**៧៦.២៧%** ក្នុងនោះស្ត្រីមានចំនួន**៦៤.១៩៤**នាក់។ (**ឧបសម្ព័ន្ធទី១**)

**ខ.៣-ការផ្សព្វផ្សាយតាមរយៈសម្ភារៈ និងតាមប្រព័ន្ធព័ត៌មាន**

- **លេខាធិការដ្ឋាន គ.ខ.ប.ជ** បានផ្សព្វផ្សាយតាមវិទ្យុ ក្រោមប្រធានបទទាក់ទងនឹងអំពើជួញដូរមនុស្ស ចំនួន**៥១**លើក **មានខេត្តៈ** (កំពត**១៦**លើក សៀមរាប០៤លើក និងកោះកុង**៣១**លើក)។
    - **ខេត្តបាត់ដំបង៖ អង្គការ Samaritan Purse** បានសហការជាមួយសមត្ថកិច្ច ចែកខិត្តប័ណ្ណផ្សព្វផ្សាយ ដល់ពលករចំណាកស្រុក**៧៩**នាក់ ស្រី**២៩**នាក់ ដែលបញ្ជូនត្រឡប់នៅព្រំដែនប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។ Ritha

### ខ.៤-ទប់ស្កាត់ រារាំងតម្រូវការសេវាកម្ម ដែលទំនោរទៅរកការជួញដូរមនុស្ស

#### ខ.៤.១-វិធានការទប់ស្កាត់តាមជំនាញរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ

- **ខេត្តបាត់ដំបង** នគរបាលការពារព្រំដែនគោកវរៈសេនាតូចលេខ៨១៧,៨១៩,៨២៣ និង៣១០ បានទប់ស្កាត់ប្រជាពលរដ្ឋបម្រុងឆ្លងដែនខុសច្បាប់ចំនួន**០១**លើក មនុស្សចំនួន**១១៤**នាក់ ស្រី**៤៨**នាក់ និងកុមារ**៣៤**នាក់។

#### ខ.៤.២-វិធានការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្ស ក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទ៖

ក្នុងខែធ្នូ ឆ្នាំ២០១៧នេះ អគ្គស្នងការដ្ឋាននគរបាលជាតិ (របាយការណ៍ពីក្រុមការងារអនុវត្តន៍ច្បាប់) និងស្នងការរាជធានី-ខេត្ត បានសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាពបង្ការទប់ស្កាត់តាមគោលដៅ ទទួលបានលទ្ធផលដូចខាងក្រោម ៖

- បច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ញាកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម និងបុគ្គលិកធ្វើការក្នុងហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន**១៩៦**គោលដៅ មានមនុស្សចំនួន**១.៥៨៨**នាក់ (ស្រី **១.៣៤០**នាក់) **កម្លាំងជំនាញអនុវត្ត នៃស្នងការដ្ឋាននគរបាលខេត្ត មាន៖** (ពោធិ៍សាត់, ស្ទឹងត្រែង កែប, ឧត្តរមានជ័យ, មណ្ឌលគិរី, រតនគិរី និងព្រះវិហារ)។
- គោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងការធ្វើអាជីកម្មផ្លូវភេទ ក្នុងនោះអំពើជួញដូរមនុស្ស ចំនួន**០៩**គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន**៦៦**គោលដៅ សរុបចំនួន**៧៥**គោលដៅ ទូទាំងរាជធានី-ខេត្ត។
- ការល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ ធ្វើបានចំនួន**២០**លើក ខេត្តអនុវត្តមាន៖ សៀមរាប ព្រៃវែង ឧត្តរមានជ័យ ស្វាយរៀង ពោធិ៍សាត់ កំពង់ធំ និងខេត្តកំពង់ស្ពឺ។

### ខ.៥.គោលនយោបាយប្រឆាំងនឹងទេសន្តរប្រវេសន៍ខុសច្បាប់ និងគ្រោះថ្នាក់

#### ខ.៥.១. វិធានការគ្រប់គ្រងបច្ចុប្បន្នភាពចំណាកស្រុក

- ***បច្ចុប្បន្នភាពស្ថិតិចំណាកស្រុក***

បច្ចុប្បន្នភាពទិន្នន័យពលករចំណាកស្រុកទៅក្រៅប្រទេស បានពិនិត្យឃើញថា នៅតែបន្តកើតមានឡើងជាក់ស្តែងក្នុងខែធ្នូ ឆ្នាំ២០១៧នេះ តួលេខមានដូចក្នុងតារាងខាងក្រោម៖

***តារាងតាមដានបច្ចុប្បន្នភាពទិន្នន័យពលករខ្មែរចំណាកស្រុក ប្រចាំខែធ្នូ***

| ប្រចាំខែ | សរុបរួម | | | | ស្របច្បាប់ | | | | មិនស្របច្បាប់ | | | | សម្គាល់ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | |
| | | | សរុប | ស្រី | | | សរុប | ស្រី | | | សរុប | ស្រី | |
| ធ្នូ | ៣២១.៥៩៧ | ១៤១.៧១២ | ៩.០១៩ | ៣.៣៧៤ | ១៧៩.២២៤ | ៨៤.៧៦០ | ១.១៨០ | ៥២៤ | ១៤២.៣៧៣ | ៥៦.៩៥២ | ៧.៨៣៩ | ២.៨៥០ | កើនឡើង ៦៤៦ |

#### ខ.៥.២ ការតាមដានស្ថិតិពលករ ដែលត្រូវបានចាប់បញ្ជូនដោយអាជ្ញាធរបរទេសតាមច្រកព្រំដែន

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានទទួលពលរដ្ឋខ្មែរដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកវិញ ចំនួន**១៧៤**លើក មនុស្សចំនួន**៣.៩៥៦**នាក់ (ស្រី**១.៣៦១**នាក់ និងកុមារ**៣៧៦**នាក់) ក្នុងនោះតាមច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិចំនួន**២០**លើក មនុស្សចំនួន**៥២**នាក់ ស្រី**២៥**នាក់ តាមច្រកទ្វារព្រំដែនកម្ពុជា-ថៃចំនួន**១៥២**លើក មនុស្សចំនួន**៣.៨៩០**នាក់ (ស្រី**១.៣៣៦**នាក់

កុមារ៣៧៦នាក់) និងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិបាវិតចំនួន០២លើក មនុស្សចំនួន១៤នាក់។

*ស្ថានភាព៖*

- **ក្រុមអនុវត្តន៍ច្បាប់**រាយការណ៍ថា មានពលរដ្ឋខ្មែរចំនួន២២៨នាក់ ត្រូវអាជ្ញាធរថៃឃាត់ខ្លួនពីបទឆ្លងដែនខុសច្បាប់ ហើយថៃឃាត់ខ្លួនលើសពីរយៈពេល១ខែមុននឹងបញ្ជូនមកកម្ពុជាវិញ។
- អគ្គបញ្ជាការដ្ឋាន ទីចាត់ការការងារព្រំដែនបានទទួល និងសម្ភាសន៍ពលរដ្ឋខ្មែរដែលអាជ្ញាធរថៃបញ្ជូនមកវិញតាមខេត្តជាប់ព្រំដែនកម្ពុជា-ថៃ ចំនួន**២.៧៩១**នាក់ ស្រី**១.០០៥**នាក់ អនីតិជន**២៩៨**នាក់។
- **ខេត្តបន្ទាយមានជ័យ** អាជ្ញាធរថៃបានបញ្ជូនពលករខ្មែរត្រឡប់មកប្រទេសកម្ពុជាវិញ ក្រោមរូបភាព «**និរទេស**» តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត សរុបមានចំនួន៨១ជើង/រថយន្ត មានមនុស្សចំនួន**៣.១៦៥**នាក់ (ស្រី**១.១០១**នាក់) ក្នុងនោះកុមារ**៣២៥**នាក់ (កុមារី**១៣៨**នាក់) បើប្រៀបធៀបនឹងខែមុនមានការថយចុះ**៩២៥**នាក់ ស្មើនឹង**២២.៦១%**។ ក្រោយពីធ្វើការសម្ភាសរួច បានឲ្យយើងដឹងថា៖
  - ចេញតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតចំនួន**៩០១**នាក់ តាមច្រករបៀងមាន**២.២៦៤**នាក់ ក្នុងនោះចេញដោយខ្លួនឯងមាន**១.២២២**នាក់ និងតាមគេនាំមាន**១.៩៤៣**នាក់។
  - សម្ភាសន៍កុមារចំនួន**៩៦៩**នាក់ (កុមារី**៣៩**នាក់) ពិនិត្យឃើញថាៈ ទៅតាមឪពុកម្តាយ**៧៣**នាក់ និងតាមបងប្អូន**២៣**នាក់។
- **ខេត្តបាត់ដំបង** ទទួលពលករខ្មែរ ដែលអាជ្ញាធរថៃចាប់បញ្ជូនមកវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិដូង ចំនួន**១១**លើក មនុស្សចំនួន**១៣៦**នាក់ ស្រី**៤០**នាក់ កុមារ**០៧**នាក់។
- **ខេត្តប៉ៃលិន** ទទួលពលករខ្មែរ ដែលអាជ្ញាធរថៃចាប់បញ្ជូនមកវិញចំនួន**២៩**លើក មនុស្សចំនួន**២៥១**នាក់ ស្រី**៩៨**នាក់។

- **ដោយឡែក យោងតាមរបាយការណ៍អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានរកឃើញជនបរទេសដែលមកធ្វើការនៅក្នុងប្រទេសកម្ពុជាដោយខុសច្បាប់ និងត្រូវបណ្តេញចេញដោយមូលហេតុៈ

- **ឆ្លងដែន និងស្នាក់នៅខុសច្បាប់** ចំនួន**២៣**លើក មនុស្សចំនួន**៤០**នាក់ (ស្រី**០៥**នាក់) មាន**១២**សញ្ជាតិ ក្នុងនោះ៖(វៀតណាម**១៣**នាក់, នីហ្សេរីយ៉ា**១៣**នាក់, ឥណ្ឌូនេស៊ី**០១**នាក់, ចិន**០៤**នាក់ អង់គ្លេស**០២**នាក់, កូរ៉េ**០១**នាក់, ហ្គាណា**០១**នាក់, មីយ៉ាន់ម៉ា**០១**នាក់, បង់ក្លាដេស**០១**នាក់,បារាំង **០១**នាក់, ឥណ្ឌា**០១**នាក់ និងរុស្ស៊ី**០១**នាក់។ ក្នុងករណីខាងលើ មុននឹងបញ្ជូនចេញទៅប្រទេសដើមវិញ ត្រូវបានបោះត្រាហាមចូលប្រទេសកម្ពុជាលើលិខិតឆ្លងដែន។
- **ការត្រួតពិនិត្យតាមសហគ្រាស និងគ្រឹស្ថាននានា តាមបណ្តារាជធានី/ខេត្ត** បានចំនួន**៧៦**គោលដៅ ពលករបរទេសចំនួន**៦៧០**នាក់ ស្រី**១៤៩**នាក់ មាន**០៤**សញ្ជាតិ៖ **មានប័ណ្ណការងារៈ** ចំនួន**៦៥៩**នាក់ ផាកពិន័យចំនួន**០៥**ក្រុមហ៊ុន, ពលករ**គ្មានប័ណ្ណការងារៈ** ចំនួន**១១**នាក់ ពិន័យជាប្រាក់ ចំនួន **៥,៥០០,០០០**រៀល (ប្រាំលានប្រាំសែនរៀលគត់)។

**ខ.៦-ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍ខ្មែរនិងជនបរទេស**

អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជន

បរទេសចំនួន១៤៣គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ បានទំនាក់ទំនងនារីខ្មែរ ដែលទៅរស់នៅជាមួយស្វាមីឯក្រៅប្រទេសតាមរយៈទូរស័ព្ទផ្ទាល់ ដើម្បីតាមដានស្ថានភាពដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍ ជាលទ្ធផលពួកគេ(រស់នៅជាមួយគ្រួសារសុខសប្បាយជាធម្មតា)។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១ ការងារអនុវត្តច្បាប់

#### គ.១.១-ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានខិតខំតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចំនួន០៨/១២ករណី (ប្រៀបធៀបនឹងខែមុនថយចុះ០៤ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន១០នាក់ (ស្រី០៣នាក់)។ សង្គ្រោះជនរងគ្រោះចំនួន៤៥នាក់ ក្នុងនោះមាន៖ អាយុក្រោម១៥ឆ្នាំ១៣នាក់ អាយុពី១៥-១៧ឆ្នាំ០៦នាក់ និងអាយុ១៨ឆ្នាំឡើង២៦នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន១៤នាក់ និងគ្រួសារចំនួន៣១នាក់)។

**១. ករណីអំពើជួញដូរមនុស្ស៖**

បង្ក្រាបបាន០៣/០២**ករណី** (កើនឡើង០១ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន០៥នាក់ ស្រី០២នាក់ ជនរងគ្រោះចំនួន**៣៧**នាក់ អាយុក្រោម១៥ឆ្នាំ០៨នាក់ អាយុ១៥-១៧ឆ្នាំ០៤នាក់ និងអាយុ១៨ឆ្នាំឡើង**២៥**នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច**១១**នាក់ និងគ្រួសារ**២៦**នាក់) ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ | ១ | ២ | |
| -អំពើលក់-ដូរមនុស្សសម្រាប់នាំឆ្លងដែន | ១ | ១ | |
| -ការជ្រើសរើសដោយមិនស្របច្បាប់សម្រាប់កេងប្រវ័ញ្ច | ១ | ២ | |
| *សរុប* | *០៣ ករណី* | *០៥ នាក់* | |

**២.អំពើធ្វើអាជីវកម្មផ្លូវភេទ៖**

បង្ក្រាបបាន០៥/១០**ករណី** ឃាត់ខ្លួនជនសង្ស័យចំនួន០៥នាក់ ស្រី០១នាក់ ជនរងគ្រោះចំនួន០៨នាក់ ក្នុងនោះមាន៖ អាយុក្រោម១៥ឆ្នាំ០៥នាក់ អាយុ១៥-១៧ឆ្នាំ០២នាក់ និងអាយុ១៨ឆ្នាំឡើង០១នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច០៣នាក់ និងគ្រួសារ០៥នាក់) ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|
| -សញ្ញារកម្ម ( ទាក់ទងនឹងពេស្យាចាកុមារ) | ១ | ១ | |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ៣ | ៣ | |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ១ | ១ | |
| *សរុប* | *០៥ ករណី* | *០៥ នាក់* | |

Ritha

## ឃ.កិច្ចការពារជនរងគ្រោះ និងការផ្ដល់សេវាគាំទ្រ

### ឃ.១-ការសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញារងគ្រោះ និងជនសង្ស័យ

- **អគ្គស្នងការដ្ឋាននគរបាលជាតិ** (របាយការណ៍តាមក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើសម្ភាសន៍ពលកររងគ្រោះចំនួន០៣នាក់(ស្រី) ក្នុងនោះមកពីប្រទេសសាំងហ្គាពួរ០១នាក់, ម៉ាឡេស៊ី០១នាក់ និងប្រទេសចិន ០៣នាក់ និងម៉ាឡេស៊ី០២នាក់ តាមការសម្ភាសជនរងគ្រោះទៅតាមរយៈមេខ្យល់ទាំងអស់។

### ឃ.២-ការទទួលជនសង្ស័យរងគ្រោះ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនិតិសម្បទា (**ក្រុមការងារការពារជនរងគ្រោះ**) ដោយមានកិច្ចសហការជាមួយអង្គការ IOM អង្គការចាប់ដៃ និងអង្គការរតនៈអ៊ិនធើនេសិនណល បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស មាតុភូមិនិវត្តន៍ប្រទេសនានា សរុបចំនួន**២១**នាក់(ស្រី**១១**នាក់) មានដូចជាៈ ប្រទេសវៀតណាម១៣នាក់ ស្រី០៥នាក់ កុមារ០៨នាក់(កុមារី០៣នាក់)ចិន០៥នាក់ និងម៉ាឡេស៊ី០៣នាក់។

### ឃ.៣-ការជួយជនរងគ្រោះ និងជនងាយរងគ្រោះ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស

- **សមាហរណកម្មជនរងគ្រោះ**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (**ក្រុមការងារការពារជនរងគ្រោះ**) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងជួយឧបត្ថម្ភពីអង្គការក្ដីសង្ឃឹម អង្គការយុត្តិធម៌ និងអង្គការរតនៈអ៊ិនធើនេសិនណល បានសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរ ទៅតាមសហគមន៍វិញចំនួន០៣នាក់(ស្រី) និងវិលត្រឡប់ទៅផ្ទះវិញដោយខ្លួនឯងចំនួន០៣នាក់។

## III. ការលើកកម្ពស់សមត្ថភាព

### ១. ក្នុងប្រទេស

#### ១.១-ការបណ្ដុះបណ្ដាល

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានសហការជាមួយជំនាញតាមក្រសួង មន្ទីរ អង្គភាព និងអង្គការដៃគូ បើកវគ្គបណ្ដុះបណ្ដាលបានចំនួន**១២**វគ្គ មានសិក្ខាកាមចូលរួមចំនួន**៤៨៦**នាក់ ក្នុងនោះមានស្ត្រី**១៩៥**នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តន៍ច្បាប់ សមាជិកគ.ខ.ប.ជ លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ មានតារាងលម្អិតខាងក្រោមៈ

*តារាងវគ្គបណ្ដុះបណ្ដាល*

| ល.រ | ស្ថាប័នអនុវត្ត និងវគ្គបណ្ដុះបណ្ដាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមនារី |
|---|---|---|---|---|
| ១ | **ខេត្តកំពត** លេខាធិការដ្ឋាន គ.ខ.ប.ជ បើកវគ្គបណ្ដុះបណ្ដាល ស្តីពីទេសន្តរប្រវេសន៍ នៅស្រុកដងទង់។ | ០២ | ៧០ | ៣៨ |
| ២ | **ខេត្តសៀមរាប** លេខាធិការដ្ឋាន គ.ខ.ប.ជ បើកវគ្គបណ្ដុះបណ្ដាលពង្រឹងសមត្ថភាពដល់មន្ត្រីនៅថ្នាក់ឃុំ សង្កាត់ ក្រុង ស្រុក ទូទាំងខេត្ត។ | ១០ | ៤១៦ | ១៥៧ |
| *សរុប* | | ***១២វគ្គ*** | ***៤៨៦នាក់*** | ***១៩៥នាក់*** |

#### ១.២-កិច្ចប្រជុំការងារដឹកនាំសម្របសម្រួលៈ

ដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ចំនួន**១៨**លើក និងលេខាធិការដ្ឋានរាជធានី-ខេត្តចំនួន**៥១**លើក សរុបកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទូទាំងប្រទេសបាន**៦៩**លើក ដោយមានអ្នកចូលរួមសរុបចំនួន**៦៦៥**នាក់ ស្រី**១៩៣**នាក់។ (**ឧបសម្ព័ន្ធទី២**)

Pitha

### ២. ក្រៅប្រទេស

#### ២.១.ចូលរួមកិច្ចប្រជុំ

- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញបំពេញបេសកកម្មជាផ្លូវរដ្ឋ នៅប្រទេសម៉ិចស៊ីកូ ចូលរួមកិច្ចប្រជុំកំពូលអង្គការសហប្រជាជាតិស្តីពីការរៀបចំកតិកាសញ្ញាជាសកល ស្តីពីទេសន្តរប្រវេសន៍ ប្រកបដោយសុវត្ថិភាពភាពស្របច្បាប់ និងប្រក្រតីភាព។
- ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិតអគ្គនាយកអន្តោប្រវេសន៍ បានដឹកនាំប្រតិភូអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំរបស់អគ្គនាយកអន្តោប្រវេសន៍ និងប្រធានកុងស៊ុលអាស៊ានលើកទី២១(21st DGICM) និងកិច្ចប្រជុំពាក់ព័ន្ធ នៅទីក្រុងវៀងច័ន្ទ សាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្រេចការងារជាលទ្ធផលជោគជ័យគួរកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ **០៤ចំណុច** និងវិធានការ **០៦ចំណុច** របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារនេះ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង និងចំណុចខ្លាំងខាងលើ យើងពិនិត្យឃើញនៅមានចំណុចប្រឈម នឹងសេសសល់មួយចំនួនដូចជា ៖

- ថ្វីត្បិតតែយើងបានបង្កើតក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នា ជាប្រព័ន្ធនិងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។

- ការធ្វើរបាយការណ៍នៅឃើតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។
- របាយការណ៍សំខាន់ណាស់សម្រាប់ក្រសួង ស្ថាប័ន អង្គភាពបើរបាយការណ៍ល្អ នោះបញ្ជាក់ថាក្រសួង ស្ថាប័ន ឬអង្គភាពនោះមានស្នាដៃ សកម្ម ហើយកិត្តិយសក្រសួង ស្ថាប័ន អង្គភាពក៏បានល្អដែរ។ ឧទាហរណ៍ ក្រសួង ស្ថាប័ន ឬអង្គភាព បានធ្វើការងារច្រើនទាក់ទងនឹងការងារអំពើជួញដូរមនុស្ស តែមន្ត្រីធ្វើរបាយការណ៍មិនយល់ ឬមិនបានសរសេរអស់នូវសកម្មភាព និងទិន្នន័យដែល ក្រសួង ស្ថាប័ន ឬអង្គភាពខ្លួនបានធ្វើ ដូច្នេះកិត្តិយស ក្រសួង ស្ថាប័ន អង្គភាពនោះក៏មិនអស់តាមរបាយការណ៍នោះដែរ។

**គ.សំណូមពរ**

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជនត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនិមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឲ្យលេខាធិការដ្ឋាន គ.រ/ខ.ប.ជ រាជធានី/ខេត្ត ល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែដើម្បីប្រសិទ្ធភាពការងារ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

**ឃ. សន្និដ្ឋាន**

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារៈ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តិនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយ

អ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែមករា ឆ្នាំ២០១៨

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដេកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។ល។

៣. រៀបចំផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(ពាក់កណ្តាលអាណត្តិទី២៖២០១៧-២០១៨)។

៤. ត្រៀមចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគីកម្ពុជា-ឥណ្ឌា និងជាមួយប្រទេសពាក់ព័ន្ធដទៃទៀត។

៥. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៦. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៧. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៨. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៩. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

១០. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

១១. បន្តរៀបចំវិធានការ "**គ្រប់គ្រងលំហូរ ពលករទេសន្តប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី**" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១២. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១៣. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

ទិសដៅបន្ថែម ដែលជាអនុសាសន៍សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងកិច្ចប្រជុំឆមាសទី១ នេះ ដែលគប្បីជំរុញអនុវត្ត ឲ្យមានប្រសិទ្ធភាព សម្រាប់ដំណាក់កាលដ៏ចាំបាច់៖

១៤. ជំរុញអនុវត្តវិធានការ ដែលដាក់ចុះដោយក្រសួងមហាផ្ទៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការបរទេស ក្នុងដំណាក់កាលនៃការជំរុញដំណោះស្រាយភាពស្របច្បាប់ដល់ពលករ ដែលនៅក្នុងប្រទេសថៃ និងការទទួលខុសត្រូវរបស់អាជ្ញាធរ សមត្ថកិច្ចពាក់ព័ន្ធ ក្នុងការជួយដល់ពលករដែលត្រូវបានបញ្ជូនត្រឡប់។

១៥. បង្កើតក្រុមការងារ ពិសេសមួយក្រោមគណៈកម្មការផ្តល់ភាពស្របច្បាប់ ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីស្រាវជ្រាវ អំពីពលករខ្មែរ ដែលមានវត្តមានក្នុងប្រទេសថៃ ស្ថានភាពស្របច្បាប់ ឬមិនស្របច្បាប់ ទីកន្លែងធ្វើការ អាស័យដ្ឋាននៅកម្ពុជា ដើម្បីងាយស្រួល ក្នុងការដោះស្រាយបញ្ហា និងទំនាក់ទំនងអប់រំ ផ្តល់សេវា និងបង្កើនភាពជឿជាក់ដល់រាជរដ្ឋាភិបាល។

១៦. រៀបចំបែងចែកក្រុមនេះ ដោយស្នើសុំបញ្ចូលជាក្រុមដែលមានបេសកកម្មពិសេស ជាអនុព័ន្ធការងារ ក្នុងរយៈពេលខ្លីមួយ ដែលនឹងត្រូវរំសាយវិញ ពេលចប់បេសកកម្ម។

១៧. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ......ខែ......ឆ្នាំ......នព្វស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី......ខែ......ឆ្នាំ២០១៨

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

## សកម្មភាពផ្សព្វផ្សាយ និងវេទិកាសាធារណៈក្នុងខែធ្នូ ឆ្នាំ២០១៧

| ល.រ | របាយការណ៍ពី | ខ្លឹមសារសកម្មភាព | អង្គភាព-ស្ថាប័នអ្នករៀបចំ | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្រី |
|---|---|---|---|---|---|---|
| 1 | ក្រុមការងារអនុវត្តន៍ច្បាប់ | ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ផ្សព្វផ្សាយច្បាប់ ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងភូមិ-ឃុំមានសុវត្ថិភាព ដល់អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូ-អ្នកគ្រូ និងសិស្សានុសិស្ស។ | ស្នងការដ្ឋាននគរបាលខេត្ត | 653 លើក | 45,849 នាក់ | 22,639 នាក់ |
| 2 | ខេត្តបាត់ដំបង | ផ្សព្វផ្សាយ ស្តីពី ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 580 លើក | 26,829 នាក់ | 13,311 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សលើស្រ្តី និងកុមារ ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 267 លើក | 8,880 នាក់ | 2,680 នាក់ |
| 3 | ខេត្តស្វាយរៀង | វេទិកាសាធារណៈ ស្តីពីទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 307 លើក | 10,514 នាក់ | 5,246 នាក់ |
| | | ផ្សព្វផ្សាយ ច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រីនិងកុមារ និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព នៅតាមរោងចក្រ តំបន់សេដ្ឋកិច្ចពិសេសតាយសេង។ | លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរការងារ និងបណ្តុះបណ្តាវិជ្ជាជីវៈខេត្ត | 4 លើក | 678 នាក់ | 309 នាក់ |
| 4 | ខេត្តសៀមរាប | ផ្សព្វផ្សាយ ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ កិច្ចការពារជនរងគ្រោះ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ មន្ទីរអប់រំយុវជន និងកីឡាខេត្ត | 49 លើក | 3,798 នាក់ | 2,404 នាក់ |
| 5 | ខេត្តកោះកុង | វេទិកាសាធារណៈ ស្តីពីទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 21 លើក | 1,078 នាក់ | 46 នាក់ |
| 6 | ខេត្តកណ្តាល | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 344 លើក | 24,902 នាក់ | 15,133 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព កិច្ចការពារជនរងគ្រោះ ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 33 លើក | 1,336 នាក់ | 936 នាក់ |

Pitha

| | | | | | | |
|---|---|---|---|---|---|---|
| 7 | ខេត្តព្រះវិហារ | ផ្សព្វផ្សាយ ស្តីពីការងារបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 4 លើក | 970 នាក់ | 682 នាក់ |
| 8 | ខេត្តឧត្តរមានជ័យ | ផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ដល់លោកគ្រូ អ្នកគ្រូ សិស្សានុសិស្សនិងប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 3 លើក | 515 នាក់ | 275 នាក់ |
| 9 | ខេត្តកំពត | ផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | | 7 លើក | 81 នាក់ | 42 នាក់ |
| 10 | ខេត្តរតនគិរី | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | ស្នងការដ្ឋាននគរបាលខេត្ត | 11 លើក | 450 នាក់ | 174 នាក់ |
| 11 | ខេត្តព្រះសីហនុ | ផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរភូមិ ក្រុមប្រឹក្សាឃុំ/សង្កាត់ លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 2 លើក | 707 នាក់ | 317 នាក់ |

សកម្មភាពសរុបចំនួន: 2,285 លើក

មនុស្សសរុបចំនួន: 126,587 នាក់

ស្រីសរុបចំនួន : 64,194 នាក់

Ritha

## ឧបសម្ព័ន្ធទី២

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន៦៩លើក) មនុស្សចំនួន៦៦៥នាក់ (ស្រី១៩៣នាក់)

| ស្ថាប័នសម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិ គ.ជ.ប.ជ | **សម្របសម្រួលចំនួន១៨លើក អ្នកចូលរួមសរុបចំនួន២៦៣នាក់ (ស្រី១៧នាក់)**<br>- កិច្ចប្រជុំផ្ទៃក្នុង ស្តីពីការបូកសរុប និងដកបទពិសោធន៍ទិវាជាតិ១២ធ្នូ ឆ្នាំ២០១៧ ដែលទទួលបានជោគជ័យ សម្រាប់អនុវត្តបន្តឆ្នាំក្រោយ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន មានសមាសភាពចូលរួមចំនួន៦៤នាក់ ស្រី១០នាក់។<br>- កិច្ចប្រជុំពិភាក្សាការងារជាមួយអង្គការដៃគូរ GVC នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន មានសមាសភាពចូលរួមចំនួន០៥នាក់ ស្រី០១នាក់។<br>- បានអញ្ជើញជាអធិបតី ក្នុងកម្មវិធីធ្វើបាឋកថា ជូនសិក្ខាកាមក្នុងវគ្គបំពាក់បំប៉នជំនាញប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន វគ្គបំប៉នជំនាញកសាងភ្នាក់ងារសម្ងាត់ផ្នែកសន្តិសុខ ក្រោមប្រធានបទយុទ្ធសាស្រ្តទប់ស្កាត់របស់រាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានសិក្ខាកាមចូលរួមចំនួន៩០នាក់។<br>- កិច្ចប្រជុំអន្តរក្រសួង ស្តីពីវិធានការបណ្តោះអាសន្នចំពោះការពពោះជំនួស នៅក្នុងដំណាក់កាលមិនទាន់មានច្បាប់ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន អ្នកចូលរួមចំនួន២០នាក់ ស្រី០៦នាក់។<br>- បានអញ្ជើញចូលរួមកិច្ចប្រជុំស្តាប់របាយការណ៍ ស្តីពីការវិភាគមុខងារការកំណត់ក្របខ័ណ្ឌវឌ្ឍនៈភាពការងារ និងបញ្ហាប្រឈម នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- កិច្ចប្រជុំអគ្គលេខាធិការដ្ឋាន គ ជ.ប.ជ.ស្តីពីការងារវិភាគមុខងារមន្ត្រី និងរចនាសម្ព័ន្ធនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅអគ្គនាយកដ្ឋាន គ.ជ.ប.ជ។<br>- កិច្ចប្រជុំ ស្តីពីការរៀបចំនិងត្រួតពិនិត្យសកម្មភាពការងារទិវាជាតិ១២ធ្នូ ឆ្នាំ២០១៧ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន (០៣លើក)។<br>- ដឹកនាំត្រួតពិនិត្យវត្តមាន វិន័យ និងសណ្តាប់ធ្នាប់របស់មន្ត្រីនគរបាល និងមន្ត្រីស៊ីវិលនៃអគ្គលេខាធិការដ្ឋាន រៀងរាល់ថ្ងៃច័ន្ទ នៃសប្តាហ៍និមួយៗ នៅអគ្គនាយកដ្ឋាន គ.ជ.ប.ជ ។<br>- ប្រជុំពិភាក្សាអំពីឯកសារកម្រងសំនួរវាយតម្លៃរាជធានី-ខេត្ត នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>- ចូលរួមប្រជុំ ស្តីពីការណែនាំដល់មន្ទីរអប់រំទូទាំង២៥រាជធានី-ខេត្ត ឲ្យប្រកាសទៅការិយាល័យអប់រំថ្នាក់ក្រុង ស្រុក និងគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជន ឲ្យរៀបចំប្រារព្ធទិវាជាតិ១២ធ្នូ នៅទូទាំងប្រទេស នៅទីស្តីការក្រសួងអប់រំ យុវជន និងកីឡា។<br>- ចូលរួមប្រជុំពិភាក្សាជាមួយនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ ដើម្បីពិនិត្យទៅលើទម្រង់នៃអនុស្សារណៈនៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋឥណ្ឌា ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- បានជួបពិភាក្សាជាមួយលេខាទូតទី២ទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៃស្ថានទូតឥណ្ឌា អំពីទម្រង់នៃអនុស្សារណៈរវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋឥណ្ឌា ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាពិសេសស្ត្រី និងកុមារ នៅនិវេសនដ្ឋានទូតឥណ្ឌាប្រចាំកម្ពុជា។<br>- ចូលរួមប្រជុំពិភាក្សា ស្តីពីសេចក្តីព្រាងសៀវភៅមេរៀនស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព នៅទីស្តីការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ |

| | |
|---|---|
| | សម្បទា។<br>- បានផ្តល់កិច្ចសម្ភាសន៍តាមការស្នើសុំរបស់សម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាល ដើម្បីសិទ្ធិកុមារ ដែលដឹកនាំសម្ភាសន៍ដោយលោក **ភាព សុជា** មន្ត្រីស្រាវជ្រាវ (ADIC) មជ្ឈមណ្ឌលវិភាគការអភិវឌ្ឍន៍ ។ កិច្ចសម្ភាសន៍ផ្តោតលើ ស្ថានភាពទូទៅរបស់កុមារ កិច្ចអន្តរាគមន៍របស់រាជរដ្ឋាភិបាលទៅលើកុមារ បញ្ហាប្រឈមក្នុងកិច្ចការពារកុមារ និរន្តរភាពនៃការគាំពារកុមារ និងអនុសាសន៍ក្នុងការឆ្លើយតបទៅនឹងកិច្ចការពារកុមារ។<br>- ចូលរួមសិក្ខាសាលាពិភាក្សា និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ ស្តីពីជំនួយទៅវិញទៅមកផ្នែកច្បាប់ក្នុងវិស័យព្រហ្មទណ្ឌ ដែលរៀបចំដោយក្រសួងយុត្តិធម៌ សហការជាអង្គការ AAPTIP ធ្វើនៅសណ្ឋាគារភ្នំពេញ ដែលមានសមាសភាពចូលរួមចំនួន**៨៥**នាក់។<br>- ចូលរួមសិក្ខាសិលាស្តីពី ការពិនិត្យលើរបកគំហើញនៃសេចក្តីព្រាងរបាយការណ៍ ស្តីពីស្ថានភាពសិទ្ធិកុមារ ឆ្នាំ២០១៧ នៅសណ្ឋាគារភ្នំពេញ។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន៥១លើក អ្នកចូលរួមសរុបចំនួន៤០២នាក់ (ស្រី១៧៦នាក់)** | |
| **ខេត្តព្រះវិហារ** | **សម្របសម្រួលចំនួន០៣លើក អ្នកចូលរួមសរុបចំនួន២៦នាក់ (ស្រី០៩នាក់)**<br>- កិច្ចប្រជុំ ស្តីពីការអនុវត្តផែនការសកម្មភាពផ្សព្វផ្សាយអបអរសាទរខួបលើកទី១១ ទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១៧ និងរៀបចំបូកសរុបរបាយការណ៍ប្រចាំឆ្នាំ២០១៧ និងលើកទិសដៅសម្រាប់អនុវត្តបន្តឆ្នាំ២០១៨ អ្នកចូលរួម**២១**នាក់ ស្រី**០៨**នាក់។<br>- កិច្ចប្រជុំ ស្តីពីការរៀបចំផែនការសកម្មភាពសម្រាប់ចុះផ្សព្វផ្សាយប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលើកទិសដៅអនុវត្តផែនការឆ្នាំ២០១៨ អ្នកចូលរួមចំនួន**០៥**នាក់ ស្រី**០១**នាក់។<br>- ចូលរួមអបអរទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១៧ នៅសាលមហោស្រពកោះពេជ្រ។ |
| **ខេត្តកំពត** | - បានបញ្ជូនក្រុមលេខាធិការដ្ឋាន០៨នាក់ ទៅចូលរួមវគ្គសិក្ខាសាលា ស្តីពីជំនាញប្រាស្រ័យទាក់ទងជាមួយប្រព័ន្ធផ្សព្វផ្សាយ និងការនិយាយជាសាធារណៈ។<br>- ចូលរួមអបអរទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១៧ នៅសាលមហោស្រពកោះពេជ្រ។ |
| **ខេត្តកោះកុង** | **សម្របសម្រួលចំនួន០៣លើក អ្នកចូលរួមសរុបចំនួន៦០នាក់ (ស្រី១១នាក់)**<br>- កិច្ចប្រជុំស្តីពីការត្រៀមរៀបចំទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១៧ អ្នកចូលរួមចំនួន**១១**នាក់ ស្រី**០៤**នាក់។<br>- កិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៧ នៅស្នងការដ្ឋាននគរបាលខេត្តកោះកុង អ្នកចូលរួមចំនួន**៤៩**នាក់ ស្រី**០៧**នាក់។<br>- ចូលរួមអបអរទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១៧ នៅសាលមហោស្រពកោះពេជ្រ។ |
| **ខេត្តកំពង់ធំ** | **សម្របសម្រួលចំនួន០៧លើក អ្នកចូលរួមសរុបចំនួន៣០នាក់ (ស្រី១៤នាក់)**<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំប្រចាំឆមាសទី២ នៅសាលប្រជុំសាលាខេត្តកំពង់ធំ អ្នកចូលរួមចំនួន**៣០**នាក់ ស្រី**១៤**នាក់។<br>- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការបង្ហាញលទ្ធផលវាយតម្លៃបញ្ចប់គម្រោង និងមេរៀនដែលរៀនសូត្របានពីគម្រោងលទ្ធភាពទទួលបានយុត្តិធម៌សម្រាប់ស្ត្រីដំណាក់កាលទី២ នៅសណ្ឋាគារ អ៊ីនធើខន ធីណិនថល រាជធានីភ្នំពេញ។<br>- បានសំដែងការគួរសម និងពិភាក្សាការងារអំពីការវាយតម្លៃកិច្ចការពារកុមារ ជាមួយអង្គការយូនីសេហ្វ។<br>- បានចូលរួមប្រជុំស្តីពី ការរៀបចំផែនការធ្វើរួមគ្នា (គ.ក.ស.ក) និងបណ្តាញអង្គការសង្គមស៊ីវិលថ្នាក់ខេត្ត នៅសាលាខេត្តកំពង់ធំ។ |

| | |
|---|---|
| | - បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ទេសន្តរប្រវេសន៍ការងារ និងសមាសភាពយេនឌ័រ នៅសាលប្រជុំមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ធំ។<br>- ចូលរួមអបអរទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១៧ នៅសាលមហោស្រពកោះពេជ្រ។ |
| ខេត្តសៀមរាប | **សម្របសម្រួលចំនួន១៦លើក អ្នកចូលរួមសរុបចំនួន៣០នាក់ (ស្រី១៥នាក់)**<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ ប្រជុំប្រចាំខែធ្នូ អ្នកចូលរួមចំនួន**៣០**នាក់ ស្រី**១៥**នាក់។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ បានប្រជុំក្រុមការងារ ដើម្បីរៀបចំទិវាជាតិលើកទី១១ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន**០២**លើក។<br>- ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ ចូលរួមប្រជុំរបស់ក្រុមការងារថ្នាក់ក្រុង ស្រុក ចំនួន**១២**លើក។<br>- ចូលរួមអបអរទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១៧ នៅសាលមហោស្រពកោះពេជ្រ។ |
| ខេត្តកណ្តាល | **សម្របសម្រួលចំនួន០៦លើក អ្នកចូលរួមសរុបចំនួន១១៥នាក់ (ស្រី៦៩នាក់)**<br>- ក្រុមការងារថ្នាក់ស្រុក រៀបចំកិច្ចប្រជុំខែធ្នូ ចំនួន**០៥**លើក អ្នកចូលរួមចំនួន**១១៥**នាក់ ស្រី**៦៩**នាក់។<br>- ចូលរួមអបអរទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១៧ នៅសាលមហោស្រពកោះពេជ្រ។ |
| ខេត្តមណ្ឌលគិរី | - កិច្ចប្រជុំស្តីពីការអប់រំផ្សព្វផ្សាយការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតាមវេទិកាសាធារណៈដល់ប្រជាពលរដ្ឋតាមបណ្តាក្រុង ស្រុក ចំនួន**០៥**លើក។<br>- ចូលរួមអបអរទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១៧ នៅសាលមហោស្រពកោះពេជ្រ។ |
| ខេត្តកំពង់ឆ្នាំង | **សម្របសម្រួលចំនួន០៣លើក អ្នកចូលរួមសរុបចំនួន៧៦នាក់ (ស្រី២៨នាក់)**<br>- ដឹកនាំនាំកិច្ចបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅបន្តឆ្នាំ២០១៨ របស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អ្នកចូលរួមចំនួន**៦៥**នាក់ ស្រី**២៣**នាក់។<br>- ដឹកនាំកិច្ចប្រជុំប្រចាំខែធ្នូ របស់លេខាធិការដ្ឋានគ.ខ.ប.ជ អ្នកចូលរួមចំនួន**១១**នាក់ ស្រី**០៥**នាក់។<br>- ចូលរួមអបអរទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១៧ នៅសាលមហោស្រពកោះពេជ្រ។ |
| ខេត្តប៉ៃលិន | - កិច្ចប្រជុំអំពីពិគ្រោះពិភាក្សាសេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ២០១៧ របស់គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្តប៉ៃលិន។<br>- ចូលរួមអបអរទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១៧ នៅសាលមហោស្រពកោះពេជ្រ។ |
| ខេត្តស្វាយរៀង | **សម្របសម្រួលចំនួន០៣លើក អ្នកចូលរួមសរុបចំនួន៥៧នាក់ (ស្រី៣០នាក់)**<br>- កិច្ចប្រជុំបូកសរុបលទ្ធផលការងារ គ ខ ប ជ រយៈពេល១០ខែ ឆ្នាំ២០១៧ អ្នកចូលរួម**៤១**នាក់ ស្រី**២១**នាក់ នៅសាលាខេត្តស្វាយរៀង។<br>- កិច្ចប្រជុំពិភាក្សាការងារត្រៀមរៀបចំទិវាជាតិ១២ធ្នូ ខួបលើកទី១១ អ្នកចូលរួម**១៦**នាក់ ស្រី**០៩**នាក់ នៅសាលាខេត្តស្វាយរៀង។<br>- ចូលរួមអបអរទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស១២ធ្នូ ឆ្នាំ២០១៧ នៅសាលមហោស្រពកោះពេជ្រ។ |

Putha